ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤០២
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨
សំណុំរឿងជំនុំជម្រះលេខៈ ៤៨៩
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩
សាលក្រមលេខៈ **១០៣ "ឈ"**
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការលេខ២
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៩:៣០នាទីព្រឹក
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៩:៣០នាទីព្រឹក

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រម ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រម ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រម ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

## ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៤០២ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **លេន** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៣ មុខរបរ ធ្វើស្រែ ឪពុកឈ្មោះ [redacted] ហ៊ុំ "រ" ម្តាយឈ្មោះ [redacted] លី "រ" ប្រពន្ធឈ្មោះ [redacted] ចាប មានកូន ០១នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន (ក្រៅឃុំ)។

២-ឈ្មោះ [redacted] **ស៊ីុយ** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរ ធ្វើស្រែ ឪពុកឈ្មោះ [redacted] នួក "រ" ម្តាយឈ្មោះ [redacted] គា "ស" ប្រពន្ធឈ្មោះ [redacted] ជៀន មានកូន ០១នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន (ក្រៅឃុំ)។

៣-ឈ្មោះ [redacted] **គ្រាក់** ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប មុខរបរ ធ្វើស្រែចំការ ឪពុកឈ្មោះ [redacted] គិត "ស" ម្តាយឈ្មោះ [redacted] សូវ "រ" ប្រពន្ធឈ្មោះ [redacted] យុត មានកូន ០៤នាក់ ប្រវត្តិផ្តន្ទាទោសដោយតុលាការ គ្មាន (ក្រៅឃុំ)។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទៈ **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ** ប្រព្រឹត្តនៅត្រង់ចំណុចនិយាមកាលេខ (៤២១០៧២-១៥១៦៩៥០) ក្នុងភូមិសាស្ត្រភូមិពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៩៧ នៃច្បាប់ស្តីពីព្រៃឈើ។**

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៥៣ អ.យ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ១៩៦៨ ពស.ព្រស ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ៧៦៦ ពស.ព្រជ (ក) ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

-**បានឃើញ** ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ដំណើររឿងហេតុកើតឡើងមានដូចតទៅ

កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ១១ថ្ងៃត្រង់ ក្រុមការងារបង្ក្រាបបទល្មើសព្រៃឈើសង្កាត់រដ្ឋបាលព្រៃឈើស្វាយលើ សហការជាមួយផ្នែករដ្ឋបាលដីក្រែងចុះបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃនៅត្រង់ចំណុចនិយាមកាលេខ (៤២១០៧២-១៥១៦៩៥០) ក្នុងភូមិសាស្ត្រភូមិពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប បានជួបប្រទះឃើញមានការកាប់រុករានដីព្រៃឈើ យកធ្វើជាកម្មសិទ្ធិទំហំ ៦០១០ម² ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ និងបានឃាត់ខ្លួនបានជនជាប់ចោទចំនួនពីរនាក់ឈ្មោះ[redacted]លេន និងឈ្មោះ [redacted] ស៊ុយ។ ក្រោយពីធ្វើការឃាត់ខ្លួនជនជាប់ចោទទាំងពីរនាក់បានឆ្លើយសារភាពថា រូបគេគឺស៊ីឈ្នួលកាប់គ្រួសព្រៃឲ្យឈ្មោះ ក្រាក់ រស់នៅភូមិប៉ោយស្នាច់ ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ហើយក៏មិនបានដឹងដីព្រៃនោះជាដីព្រៃដែលរដ្ឋបានហាមឃាត់នោះទេ។

## នាពេលសវនាការ

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]លេន បានឆ្លើយថាៈ កាលពីថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ ក្រាក់ ភេទប្រុស រស់នៅភូមិប៉ោយស្នាច ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប បានប្រើខ្លួន និងឈ្មោះ ស៊ុយ ទៅកាប់ព្រៃនៅក្នុងដីរបស់គាត់ ដោយខ្លួនស៊ីឈ្នួលពីគាត់១ហិកតា ២០ម៉ឺនរៀល ស្ថិតនៅភ្នំមួយរយ។ ក្រោយមកខ្លួន និងឈ្មោះ ស៊ុយ បាននាំគ្នាកាប់គ្រួសព្រៃរហូតដល់ថ្ងៃទី០៦ បានទំហំ១ហិកតាជាង លុះថ្ងៃទី០៦ វេលាម៉ោង១០ ខ្លួន និងឈ្មោះ ស៊ុយ បាននាំគ្នាឈប់សម្រាកហូបទឹក ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនពួកខ្លួនតែម្តង ពួកខ្លួនមិនបានដឹងថាសមត្ថកិច្ចឃាត់ខ្លួនពួកខ្លួនរឿងអ្វីទេ ក្រោយមកទើបសមត្ថកិច្ចបានប្រាប់ថាពួកខ្លួនបានកាប់ព្រៃក្នុងតំបន់ហាមឃាត់។



Scanned with CamScanner

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ុយ បានឆ្លើយថាៈ កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ឈ្មោះ ក្រាក់ ភេទប្រុស រស់នៅភូមិប៉ោយស្នាច ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប បានប្រើខ្លួន និងឈ្មោះ លេន ទៅកាប់ព្រៃនៅក្នុងដីរបស់គាត់ ដោយខ្លួនស៊ីឈ្នួលពីគាត់មួយហិកតា ២០ម៉ឺនរៀល ស្ថិតនៅភ្នំមួយរយ។ ក្រោយមកខ្លួន និងឈ្មោះ លេន បាននាំគ្នាកាប់គ្រួសព្រៃរហូតដល់ថ្ងៃទី០៦ បានទំហំ១ហិកតាជាង លុះថ្ងៃទី០៦ វេលាម៉ោង១០ ខ្លួន និងឈ្មោះ លេន បាននាំគ្នាឈប់សម្រាកហូបទឹក ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនពួកខ្លួនតែម្តង ពួកខ្លួនមិនបានដឹងថាសមត្ថកិច្ចឃាត់ខ្លួនពួកខ្លួនរឿងអ្វីទេ ក្រោយមកទើបសមត្ថកិច្ចបានប្រាប់ថាពួកខ្លួនបានកាប់ព្រៃក្នុងតំបន់ហាមឃាត់។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ក្រាក់ បានឆ្លើយថាៈ ចំពោះដីដែលខ្លួនឲ្យឈ្មោះ [redacted] ស៊ុយ និងឈ្មោះ [redacted] លេន ទៅកាប់ឆ្ការដាំដំណាំដំឡូងមីនោះជាដីកម្មសិទ្ធិរបស់ឈ្មោះ [redacted] លាងស៊ីម ភេទស្រី ដែលខ្លួនបានសុំគាត់ធ្វើដំណាំដោយមិនបានជួលគាត់ទេ។ លុះដល់ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted] ស៊ុយ និងឈ្មោះ [redacted] លេន ទៅកាប់ឆ្ការដីនោះ ដែលស្ថិតនៅភូមិត្រពាំងពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប ដោយខ្លួនឲ្យឈ្នួលពួកគាត់ក្នុងមួយហិកតាចំនួន២០ម៉ឺនរៀល និងបានធ្វើលិខិតស្នើសុំខាងរដ្ឋអំណាចផងដែរ។ លុះដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ស្រាប់តែមានសមត្ថកិច្ចទៅឃាត់ខ្លួនឈ្មោះ [redacted] ស៊ុយ និងឈ្មោះ [redacted] លេន យកទៅតុលាការតែម្តង ហើយខ្លួនក៏មិនបានដឹងថាដីដែលខ្លួនសុំឈ្មោះ [redacted] លាងស៊ីម ធ្វើដំណាំនោះជាដីរបស់រដ្ឋទេ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុដូច្នេះតំណាងអយ្យការសូមរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៣ អ.យ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

ផ្អែកតាមកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យកស្តុតាង និងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ និងប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] លេន និងឈ្មោះ [redacted] ស៊ុយ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានទៅកាប់ឆ្ការព្រៃនៅចំណុចភូមិសាស្ត្រភូមិពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៨ មកម្ល៉េះ ដោយការកាប់ឆ្ការនោះ គឺពួកខ្លួនស៊ីឈ្នួលកាប់ឲ្យឈ្មោះ [redacted] ក្រាក់ ហើយឈ្មោះ [redacted] ក្រាក់ ក៏បានឆ្លើយសារភាពដូចគ្នាផងដែរថា ខ្លួនបានប្រើឲ្យឈ្មោះ [redacted] លេន និងឈ្មោះ [redacted] ស៊ុយ កាប់ឆ្ការព្រៃដើម្បីដាំដំឡូងមី ហេតុដូច្នេះមានន័យថាជនជាប់ចោទទាំងបីនាក់ពិតជាបានប្រព្រឹត្តបទល្មើស **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ** ប្រាកដមែន គប្បីតុលាការពិនិត្យ និងពិចារណា។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ៣៥៣ អ.យ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិនិត្យ និងសម្រេចតាមការស្នើសុំ។

-អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ទៅលើសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ ទ្រព្យសម្បត្តិរដ្ឋ និងសន្តិសុខសង្គម ប្រាកដមែន។

-មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមានបញ្ហាស្មារតី គឺបញ្ជាក់បានថាជនជាប់ចោទមានសតិល្អត្រឹមត្រូវ និងយល់ដឹងបានពីអំពើដែលខ្លួនបានប្រព្រឹត្ត គឺជាបទល្មើសព្រហ្មទណ្ឌ តែជននេះនៅតែប្រព្រឹត្ត។

-មានភស្តុតាងដាក់បន្ទុក ជាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] លេន ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] ស៊ុយ ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ក្រាក់ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ ពីបទៈ **កាប់រានព្រៃ ឈូសឆាយដីព្រៃហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ** ប្រព្រឹត្តនៅត្រង់ចំណុចនិយាមកាលេខ (៤២១០៧២-១៥១៦៩៥០) ក្នុងភូមិសាស្ត្រភូមិពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៩៧** នៃច្បាប់ស្តីពីព្រៃឈើ។

-វត្ថុចាប់យករួមមានៈ គោយន្តចំនួន ០១គ្រឿង ,ម៉ូតូម៉ាក C-125 ពណ៌ខ្មៅ សេរីឆ្នាំ ២០១៣ ពាក់ស្លាកលេខ សៀមរាប 1M-9409 ចំនួន ០១គ្រឿង ,កាំបិតខ្មែរចំនួន ០២ដើម និងពូថៅចំនួន ០១ដើម ជាមធ្យោបាយប្រព្រឹត្តបទល្មើស ត្រូវបានរក្សាទុកជាបណ្តោះអាសន្ននៅខណ្ឌរដ្ឋបាលព្រៃឈើសៀមរាប។

## សាលាដំបូង ខេត្តសៀមរាប
## វិនិច្ឆ័យសេចក្តី

I-ផ្តន្ទាទោសជនជាប់ចោទ

១-ឈ្មោះ[redacted] **លេន** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

២-ឈ្មោះ[redacted] **ស៊ុយ** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

៣-ឈ្មោះ[redacted] **ក្រាក់** ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ (សាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់ម្នាក់ៗរយៈពេល ០៥ (**ប្រាំ**) **ឆ្នាំ**។

ពីបទៈ **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ** ប្រព្រឹត្តនៅត្រង់ចំណុចនិយាមកាលេខ (៤២១០៧២-១៥១៦៩៥០) ក្នុងភូមិសាស្ត្រភូមិពពេល ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៩៧** នៃច្បាប់ស្តីពីព្រៃឈើ។



Scanned with CamScanner

II-វត្ថុចាប់យករួមមាន៖ គោយន្តចំនួន ០១គ្រឿង ,ម៉ូតូម៉ាក C-125 ពណ៌ខ្មៅ សេរី ឆ្នាំ ២០១៣ ពាក់ស្លាកលេខ សៀមរាប 1M-9409 ចំនួន ០១គ្រឿង ,កាំបិតខ្មែរចំនួន ០២ដើម និងពូថៅចំនួន ០១ដើម **ត្រូវសម្រេចរឹបអូស។**

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប ,ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

សៀមរាប ,ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner